**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីជូនដំណឹង
## ស្តីពីពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០២២

**ថ្ងៃទី២៨-២៩ ខែតុលា ឆ្នាំ២០២២ នៅអគារពាណិជ្ជកម្ម និងពិព័រណ៍កោះពេជ្រ**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់ក្រសួង ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារ សិស្ស-និស្សិត និងសាធារណជនមេត្តាជ្រាបថា ដោយមានកិច្ចសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.) រាជធានីភ្នំពេញ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) និងគាំទ្រដោយអង្គការអន្តរជាតិខាងការងារ (ILO) ក្រសួងនឹងរៀបចំ **ពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០២២** (National Career and Productivity Fair 2022) រយៈពេល ២ថ្ងៃ ចាប់ពីថ្ងៃសុក្រ ៤កើត ដល់ថ្ងៃសៅរ៍ ៥កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៨-២៩ ខែតុលា ឆ្នាំ២០២២ ពីម៉ោង ០៨:០០នាទីព្រឹក ដល់ម៉ោង ២០:០០នាទីយប់ **នៅអគារពាណិជ្ជកម្ម និងពិព័រណ៍កោះពេជ្រ** រាជធានីភ្នំពេញ ព្រមទាំងការរៀបចំឱ្យដាក់ពាក្យស្វែងរកការងារតាមប្រព័ន្ធអនឡាញ ដែលមានគេហទំព័រពិព័រណ៍ការងារ **www.careerfair.nea.gov.kh**។ ព្រឹត្តិការណ៍ការងារដ៏ធំជាងគេប្រចាំឆ្នាំ២០២២នេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីៈ

- បង្កើតជាវេទិកាប្រមូលផ្តុំឱកាសការងារដ៏ច្រើនសន្ធឹកសន្ធាប់នៅមួយកន្លែងងាយស្រួល និងអាចចូលមើលតាមប្រព័ន្ធអនឡាញពីគ្រប់ទីកន្លែងទូទាំងប្រទេស សម្រាប់និយោជក អ្នកស្វែងរកការងារ និងអ្នកផ្តល់ការអប់រំបណ្តុះបណ្តាល
- និយោជកអាចតាំងបង្ហាញ និងផ្សព្វផ្សាយពីតម្រូវការជ្រើសរើសកម្លាំងពលកម្ម ដើម្បីទាក់ទាញអ្នកស្វែងរកការងារដែលមានសមត្ថភាពជំនាញ និងសក្តានុពលស្របតាមតម្រូវការ
- អ្នកស្វែងរកការងារអាចដាក់ពាក្យ និងសម្ភាសការងារផ្ទាល់ និងតាមប្រព័ន្ធអនឡាញព្រមទាំងទទួលបានព័ត៌មានអំពីឱកាសការងារ និងឱកាសក្នុងការអភិវឌ្ឍជំនាញ
- អ្នកផ្តល់ការអប់រំបណ្តុះបណ្តាលអាចផ្សព្វផ្សាយកម្មវិធីសិក្សា វគ្គសិក្សា និងកម្មវិធីអភិវឌ្ឍជំនាញគ្រប់ប្រភេទ
- លើកកម្ពស់ការយល់ដឹង និងបណ្តុះគំនិតអំពីការបង្កើនផលិតភាពតាមរយៈសិក្ខាសាលាចែករំលែកចំណេះដឹង និងបទពិសោធន៍ ដោយវាគ្មិនជាតិ-អន្តរជាតិល្បីៗ
- បង្កើតវេទិកាសម្រាប់ពង្រីកបណ្តាញទំនាក់ទំនងផ្នែកធនធានមនុស្ស (HR Networking)។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រប់ក្រសួង ស្ថាប័ន និយោជក អ្នកផ្តល់ការអប់រំបណ្តុះបណ្តាល អ្នកស្វែងរកការងារ សិស្ស-និស្សិត និងសាធារណជនជ្រាបជាព័ត៌មាន និងសូមទំនាក់ទំនងមកកាន់ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខទូរស័ព្ទ ០១៧ ៨៧១ ៨០៧/ ០១៦ ៤៣៨ ៨៤៣ ឬចូលមើលគេហទំព័រ **www.careerfair.nea.gov.kh**។

ថ្ងៃ សុក្រ ១៥កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០២២